ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសុខាភិបាល

លេខ.០៧៤.២អបនស/ឱអបស

រាជធានីភ្នំពេញ, ថ្ងៃទី ០៦ ខែ ០៩ ឆ្នាំ២០០៩..

## រដ្ឋមន្ត្រី ក្រសួងសុខាភិបាល

## ជំរាបមក

## លោក_លោកស្រី នាយកគ្រឹះស្ថានផលិតឱសថ ការិយាល័យតំណាងរោងចក្រផលិតឱសថ និងគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថទាំងអស់ ក្នុងព្រះរាជាណាចក្រកម្ពុជា.

កម្មវត្ថុ : បណ្តាពង្រឹងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ និងគ្រឿងសំអាង ។

យោង : .ព្រះរាជក្រម ជស.រកម.០៦៩៦/០២ ចុះថ្ងៃទី ១៧ មិថុនា ១៩៩៦ ក្រភាសឱ្យប្រើច្បាប់ ស្តីពីការគ្រប់គ្រងឱសថ

.ព្រះរាជក្រម នស/រកម/១២០៧/០៣៧ ចុះថ្ងៃទី ២៨.១២.២០០៧ ស្តីពីវិសោធន៍កម្មច្បាប់ស្តីពីការគ្រប់គ្រងឱសថ

.ប្រកាសលេខ ៤៣ អ.ប.ស/ឱ.អ.ប.ស ចុះថ្ងៃទី ៣១.៣.៩៩ របស់ក្រសួងសុខាភិបាល ស្តីពីល័ក្ខខ័ណ្ឌ ក្នុងការផ្សព្វផ្សាយឱសថនិងផលិតផលដែលមានគុណភាពក្នុងការបង្ការ ឬព្យាបាលជម្ងឺ

.ប្រកាសរួមក្រសួងសុខាភិបាល និងក្រសួងពត៌មាន ចុះថ្ងៃទី ២១.០២.២០០៦ ស្តីពីល័ក្ខខ័ណ្ឌក្នុងការផ្សព្វផ្សាយពាណិជ្ជកម្មឱសថសម័យ ឱសថបូរាណ គ្រឿងសំអាង ផលិតផលសំរាប់ចិញ្ចឹមទារក ថ្នាំជក់ និងសេវាឯកជនក្នុងវិស័យវេជ្ជសាស្ត្រ អមវេជ្ជសាស្ត្រ និងជំនួយវេជ្ជសាស្ត្រ ។

សេចក្តីដូចបានជំរាបក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមជំរាបលោក.លោកស្រី ជានាយកគ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថឱ្យបានជ្រាបថា : បច្ចុប្បន្ននេះមានគ្រឹះស្ថានផលិតឱសថ និងគ្រឹះស្ថានអាហរ័ណ នីហរ័ណឱសថមួយចំនួនធំ បានធ្វើការផ្សព្វផ្សាយពាណិជ្ជកម្មឱសថ និងគ្រឿងសំអាងរបស់ខ្លួន តាមគ្រប់រូបភាពដោយគ្មានការអនុញ្ញាតពីក្រសួងសុខាភិបាល និង បិទផ្ទាំងរូបភាពពាណិជ្ជកម្មគ្រប់ទីកន្លែងមិនសមស្រប ដូចជាតាមមធ្យោបាយដឹកជញ្ជូន បង្គោលភ្លើង ចងបដាកាត់ផ្លូវ ឬធ្វើជាឃ័ហោរ ឱសថស្ថាន.រង ។ល។

ដើម្បីទប់ស្កាត់បាតុភាពខាងលើ ក្រសួងសុខាភិបាលមានវិធានការ និងណែនាំដូចខាងក្រោម :

១.ការផ្សព្វផ្សាយមិនអាចអនុញ្ញាតឱ្យប្រព្រឹត្តទៅតាមរយៈ ÷

.បិទតាមទូរទូរស័ព្ទសាធារណៈ មធ្យោបាយដឹកជញ្ជូនគ្រប់ប្រភេទ

.លើអាវយឺត មួក បដាចងកាត់ទទឹងថ្នល់ ឬតាមបង្គោលភ្លើង ឬទីសាធារណៈ ឬតាមអាគារផ្សេងៗ

.បិទលើធាកពេលប្រគុំតន្ត្រី ឬពេលធ្វើសំភាសន៍ក្នុងកម្មវិធីផ្សេងៗ តាមបុស្តិ៍ទូរទស្សន៍នានា

.បិទក្បែរស្លាកសញ្ញាឱសថស្ថាន.រង ឬធ្វើជាស្លាកសញ្ញាឱសថស្ថាន.រង

563

-បិទតាមទូរថ្នាំ ជារនាំងចាំងថ្ងៃ ជាផ្ទាំងរូបភាពបិទ ឬបញ្ឈរមុខឱសថស្ថាននិងគ្រឹះស្ថាន
ផ្សេងៗទៀត

-ការសំភាសន៍របស់ពិធីករ-ពិធីការិនី តាមវិទ្យុ-ទូរទស្សន៍

-ការធ្វើអត្ថាធិប្បាយបន្ថែម របស់ពិធីករ-ពិធីការិនី ។ល។

២-ការផ្សព្វផ្សាយអាចអនុញ្ញាតបានតែ :

-តាមរយៈវិទ្យុ-ទូរទស្សន៍-សារព័ត៌មាន-ទស្សនាវដ្តី-សិក្ខាសាលា ព្រឹត្តិបត្រវេជ្ជសាស្ត្រ-ឱសថសាស្ត្រ
និងទិវាវេជ្ជសាស្ត្រ-ឱសថសាស្ត្រនានា

-ខិតប័ណ្ណ ដែលមានទំហំត្រឹមក្រដាស A4 សំរាប់ចែកចាយដល់គ្រូពេទ្យ ឬដាក់នៅតាមឱសថស្ថាន-រង
ដើម្បីអតិថិជនបានយល់ដឹង ។

៣-រាល់ខ្លឹមសារនិងរូបភាពនៃការផ្សព្វផ្សាយ អាចអនុញ្ញាតបានលុះត្រាតែមានការយល់ព្រមពីក្រសួង
សុខាភិបាលជាមុនសិន ។

ទទួលបានសេចក្តីណែនាំនេះ ក្រសួងសុខាភិបាលសង្ឃឹមថា :

-គ្រឹះស្ថានផលិតឱសថ ការិយាល័យតំណាងរោងចក្រផលិតឱសថ និងគ្រឹះស្ថានអាហារីណេ
នីហារីណេឱសថទាំងអស់ ត្រូវបញ្ឈប់នូវសកម្មភាពផ្សព្វផ្សាយពាណិជ្ជកម្មឱសថខុសច្បាប់ខាងលើ
ព្រមទាំងធ្វើការកែប្រែការផ្សព្វផ្សាយពាណិជ្ជកម្មឱសថឱ្យបានសមស្របតាមច្បាប់ដូចយោងខាងលើ ។
ក្នុងករណីរឹងរូស ក្រសួងនឹងបញ្ឈប់ការចេញនូវអាជ្ញាប័ណ្ណនាំចូលឱសថ និងផ្អាកសកម្មភាពក្រុមហ៊ុន
របស់អស់លោក-លោកស្រី ។

-គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង ត្រូវធ្វើការណែនាំ តាមដាន ត្រួតពិនិត្យការផ្សព្វផ្សាយពាណិជ្ជកម្ម
ឱសថ សំដៅអនុវត្តសេចក្តីណែនាំនេះឱ្យមានប្រសិទ្ធភាព ។

សូមលោក-លោកស្រីនាយក ទទួលនូវការរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ ។

វេជ្ជ.នុត-សុខុម

<u>ចម្លងជូន</u> :

-អគ្គនាយកដ្ឋានបច្ចេកទេសសុខាភិបាល
-នាយកដ្ឋានឱសថ-ចំណីអាហារ-បរិក្ខារពេទ្យ និងគ្រឿងសំអាង
-គ្រប់មន្ទីរសុខាភិបាលខេត្ត-ក្រុង
"ដើម្បីមុខការ"
-គ្រប់គ្រឹះស្ថានផលិតឱសថ
-គ្រប់ការិយាល័យតំណាងរោងចក្រផលិតឱសថ
-គ្រប់គ្រឹះស្ថានអាហារីណេ នីហារីណេឱសថ
"ដើម្បីអនុវត្ត"
-កាលប្បវត្តិ
-ឯកសារ

564